**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA

Kingdom of Wonder

feel the warmth

**ក្រសួងទេសចរណ៍**

លេខ ១៨៩ សរណ

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង

## ស្តីពី

## ការផ្តល់ចំណាត់ថ្នាក់សណ្ឋាគារដោយភ្ជាប់ជាមួយការស្នើសុំអាជ្ញាប័ណ្ណទេសចរណ៍សណ្ឋាគារ

**យោង៖** - ព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍

- អនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៤ ស្តីពីចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍
- សេចក្តីជូនដំណឹងលេខ ២២០ សជណ.អទច ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៥ ស្តីអំពីការដាក់ពាក្យស្នើសុំវាយតម្លៃចំណាត់ថ្នាក់សណ្ឋាគារតាមរយៈប្រព័ន្ធព័ត៌មានវិទ្យាអនឡាញ
- សេចក្តីជូនដំណឹងលេខ០៨៤ សជណ.អទច ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៧ អំពីលទ្ធផលសន្និបាតសរុបការងារឧស្សាហកម្មទេសចរណ៍ឆ្នាំ ២០១៦ និងទិសដៅការងារបន្តឆ្នាំ២០១៧
- ប្រកាសរួមលេខ២៦២ សហវ.ប្រក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៧ ស្តីពីការពិន័យអន្តរការណ៍ជាប្រាក់ចំពោះអ្នកប្រព្រឹត្តល្មើសច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីទេសចរណ៍រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងទេសចរណ៍ ។

ក្នុងគោលបំណងពង្រឹងគុណភាពសេវាកម្មស្នាក់នៅទេសចរណ៍ឱ្យសមស្របតាមប្រព័ន្ធស្តង់ដាចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍កម្ពុជា និងឆ្លើយតបទៅនឹងកំណើនភ្ញៀវទេសចរមកស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលកំពុងមានការកើនឡើងជារៀងរាល់ឆ្នាំ ក្រសួងទេសចរណ៍ គណៈកម្មការរៀបចំវាយតម្លៃចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍(គ.រ.ច) មានកិត្តិយសសូមជម្រាបជូនដល់ម្ចាស់មូលដ្ឋានអាជីវកម្មសណ្ឋាគារអស់ឱ្យបានជ្រាបដូចតទៅ៖

១. ម្ចាស់ ឬប្រតិបត្តិករទេសចរណ៍ដែលប្រកបអាជីវកម្មសណ្ឋាគារទាំងអស់ ត្រូវតែមានអាជ្ញាបណ្ណទេសចរណ៍ និងមានចំណាត់ថ្នាក់សណ្ឋាគារស្របតាមប្រព័ន្ធស្តង់ដាចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍កម្ពុជា។

២. ការស្នើសុំអាជ្ញាបណ្ណទេសចរណ៍សណ្ឋាគារថ្មី ឬបន្តនឹងត្រូវភ្ជាប់ជាមួយនូវចំណាត់ថ្នាក់សណ្ឋាគារថ្នាក់ផ្កាយ១ ជូនដល់មូលដ្ឋានអាជីវកម្មសណ្ឋាគារនោះផងដែរ។ កម្រៃសេវាសាធារណៈសម្រាប់នីតិវិធីត្រួតពិនិត្យ និងផ្តល់ចំណាត់ថ្នាក់ផ្កាយ១ជាបន្ទុករបស់មូលដ្ឋានអាជីវកម្ម។

ដីឡូត៍លេខ៣A ផ្លូវលេខ១១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: + ៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: + ៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org

៣. ម្ចាស់ ឬអ្នកគ្រប់គ្រងមូលដ្ឋានអាជីវកម្មសណ្ឋាគារទាំងឡាយណាដែលយល់ឃើញថាលក្ខខណ្ឌសម្បទាសណ្ឋាគាររបស់ខ្លួនមានលក្ខណៈខ្ពស់ជាងចំណាត់ថ្នាក់ផ្កាយ១ ម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្មសណ្ឋាគារនោះមានសិទ្ធិសម្រេចដាក់ពាក្យស្នើសុំវាយតម្លៃចំណាត់ថ្នាក់សណ្ឋាគារនូវថ្នាក់ផ្កាយណាមួយដែលខ្លួនយល់ថាសមស្រប។ ករណីនេះ ម្ចាស់ ឬអ្នកគ្រប់គ្រងត្រូវគោរពតាមនីតិវិធីដាក់ពាក្យស្នើសុំចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍តាមសេចក្តីជូនដំណឹងលេខ ២២០ សជណ.អទច ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០១៥ ស្តីអំពីការដាក់ពាក្យស្នើសុំវាយតម្លៃចំណាត់ថ្នាក់សណ្ឋាគារតាមរយៈប្រព័ន្ធព័ត៌មានវិទ្យាអនឡាញ។

៤. ក្នុងករណីដែលម្ចាស់ ឬអ្នកគ្រប់គ្រងសម្រេចដាក់ពាក្យស្នើសុំចំណាត់ថ្នាក់សណ្ឋាគារនូវចំណាត់ថ្នាក់ផ្កាយដែលធំជាងផ្កាយ១ ការសម្រេចដាក់ពាក្យនោះ គឺត្រូវធ្វើស្របគ្នានឹងកាលបរិច្ឆេទដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍សណ្ឋាគារថ្មី ឬបន្តនោះ។

ទទួលបានសេចក្តីជូនដំណឹងនេះ ក្រសួងទេសចរណ៍មានសង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ ឬអ្នកគ្រប់គ្រងមូលដ្ឋានអាជីវកម្មសណ្ឋាគារទាំងអស់ ត្រូវចូលរួមអនុវត្តតាមស្មារតីនៃសេចក្តីជូនដំណឹងនេះប្រកបដោយការទទួលខុសត្រូវខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**កន្លែងទទួល៖**

- គ្រប់សាលារាជធានី ខេត្ត

**“ដើម្បីជូនជ្រាប”**

- គ្រប់មន្ទីរទេសចរណ៍រាជធានី ខេត្ត

**“ដើម្បីជូនជ្រាប និងអនុវត្ត”**

- សហព័ន្ធទេសចរណ៍កម្ពុជា CTF
- សមាគមសណ្ឋាគារកម្ពុជា CHA
- មូលដ្ឋានអាជីវកម្មសណ្ឋាគារ

**“ដើម្បីអនុវត្ត”**

- ឯកសារកាលប្បវត្តិ